# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

---

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## ចំណាត់ការសន្តិសុខ និងការផ្តល់សេវាសាធារណៈនៅអំឡុងពេល មហាបាតុកម្មអហិង្សា

ភ្នំពេញ, ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជា មានការខកចិត្តយ៉ាងខ្លាំងចំពោះស្ថាប័នជំនាញមួយចំនួនរបស់រាជរដ្ឋាភិបាលកម្ពុជាខកខានផ្តល់សេវាចាំបាច់រួមមាន ការផ្តល់ព័ត៌មាន ជំនួយសង្គ្រោះបឋម និងបន្ទាន់ដល់ជនរងគ្រោះជាបាតុករ និងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីព្រឹត្តិការណ៍ វិបត្តិនយោបាយនៅក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ជាពិសេសព្រឹត្តិការណ៍នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣។ ជាការពិតសេវារដ្ឋទាំងនេះ ត្រូវបានបង្កើត និងមានដំណើរការបានដោយសារតែការបង់ពន្ធរបស់ប្រជាពលរដ្ឋទូទៅ ប៉ុន្តែសេវាទាំងនេះមានលក្ខណៈលំអៀង និងរើសអើងខាងសង្គម និងនយោបាយ។ ករណីជាក់ស្តែងនៅពេលមានជនរងគ្រោះរងរបួសដោយសារការបាញ់ប្រហារ ប៉ុន្តែគ្មានសេវាសុខាភិបាលរបស់រដ្ឋបានមកជួយសង្គ្រោះបន្ទាន់នោះទេ។ សំខាន់ជាងនេះទៅទៀតយើងពុំឃើញមានសេវាកាកបាទក្រហម និងសេវាសុខាភិបាលរបស់រដ្ឋមានការត្រៀម ឬផ្តល់ជំនួយសង្គ្រោះបឋមដល់ជនរងគ្រោះឡើយ។ ដោយឡែក ទូរទស្សន៍ជាតិក៏មិនបានផ្សាយ និងផ្តល់ព័ត៌មានអំពីព្រឹត្តិការណ៍នោះជូនប្រជាពលរដ្ឋ និងក្រុមគ្រួសារជនរងគ្រោះឡើយ។

ទន្ទឹមនឹងនេះ បន្ទប់ស្ថានការណ៍បានពិនិត្យឃើញនូវការខ្វះអព្យាក្រឹតភាព និងវិជ្ជាជីវៈរបស់អាជ្ញាធរមានសមត្ថកិច្ចចំពោះចំណាត់ការសន្តិសុខ និងព្រមទាំងចំណាត់ការដោយមិនសមាមាត្ររវាងកងកំលាំងចម្រុះ និងសកម្មភាពរាំងប្រជាពលរដ្ឋ និងការចេញសេចក្តីថ្លែងការណ៍មិនទទួលខុសត្រូវលើហេតុការណ៍ដែលបានកើតឡើង។ ករណីជាក់ស្តែង ចំណាត់ការលើសកម្មភាពតវ៉ានៅចំណុចស្ពានក្បាលថ្នល់កាលពីយប់ថ្ងៃទី១៥ ខែកញ្ញា ដែលបានធ្វើឲ្យមនុស្សម្នាក់ស្លាប់នៅនឹងកន្លែង និងជនស៊ីវិលប្រមាណ១០នាក់ផ្សេងទៀតបានរងរបួសធ្ងន់ ដែលជាករណីបានកើតមានដ៏គួរឲ្យសោកស្តាយ។

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជា សូមកោតសរសើរសកម្មជន និងអ្នកស្ម័គ្រចិត្តច្រើនរយនាក់របស់អង្គការ សមាគមមិនមែនរដ្ឋាភិបាលជាច្រើនដែលបានចូលរួមយ៉ាងសកម្ម និងប្រើអស់លទ្ធភាព និង

សមត្ថភាពក្នុងការផ្តល់សេវាដល់ជនរងគ្រោះ រួមទាំងសេវាសង្គ្រោះបឋម ធ្វើយុទ្ធនាការអហិង្សាដើម្បីសន្តិភាព ការសង្កេតឃ្លាំមើលការរំលោភសិទ្ធិនយោបាយ និងកិច្ចសហការជំនួយមនុស្សធម៌ដល់គ្រួសារ និងជនរងគ្រោះ ដោយគ្មានការរើសអើង។ ជាក់ស្តែងក្រុមអង្គការ សមាគមមិនមែនរដ្ឋាភិបាលបានខិតខំជួយការពារសិទ្ធិរបស់បាតុករ ប្រជាពលរដ្ឋស្លូតត្រង់ សមត្ថកិច្ច អ្នកវិភាគនយោបាយ និងអ្នកនយោបាយ ដែលទទួលរងរបួស ឬរងឥទ្ធិពលគ្រាប់បែកផ្សែង ការបាញ់ប្រហារពីអាជ្ញាធរ ការរំខានដល់ការធ្វើដំណើរ និងការហ៊ុំព័ទ្ធដោយហ្វូងមនុស្ស។

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជា សូមទាមទារចំពោះរាជរដ្ឋាភិបាលមានគណនេយ្យភាព និងការទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋទូទៅ ដោយមិនមានការរើសអើងទៅនិន្នាការនយោបាយ ដោយពង្រឹងសេវាសាធារណៈ និងចំណាត់ការសន្តិសុខសាធារណៈ ដោយធានាឲ្យមានអព្យាក្រឹតភាព និងវិជ្ជាជីវៈរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋនៅរាល់ព្រឹត្តិការណ៍ទាំងឡាយជាដាច់ខាត។

**<u>ព័ត៌មានបន្ថែមសូមទាក់ទង៖</u>**


| | | |
|---|---|---|
| ១.លោក ធន សារាយ | ប្រធាននៃសមាគមអាដហុក ADHOC | ០១៦ ៨៨ ០០ ៨៨ |
| ២.លោកស្រី រស់ សុភាព | នាយិកាអង្គការ GADC | ០១២ ៦២ ៧៨ ៥៧ |
| ៣.លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃ CHRAC | ០១២ ៩០ ១១ ៩៩ |
| ៤.លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៩៥ ៩៦ ៦៦ |
| ៥.លោក ឈិត សំអាត | នាយកប្រតិបត្តិ NGO Forum | ០១២ ៩២ ៨៥ ៨៥ |
| ៦.លោក សឿង សារឿន | នាយកប្រតិបត្តិអង្គការ CCC | ០១៦ ៩០ ០៥ ០៣ |
| ៧.លោក សួន ប៊ុនស័ក្តិ | អគ្គលេខាធិការនៃ CHRAC | ០៩២ ៣៤ ៤៣ ៥៧ |
| ៨.លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | ០១២ ៨០ ១២ ៣៥ |
| ៩.លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | ០៦០ ៤០ ៩៩ ៩៩ |
| ១០.លោក អ៊ូ វីរៈ | ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | ០១២ ៤០ ៤០ ៥១ |
| ១១.លោក យ៉ង់ គិមអេង | នាយកប្រតិបត្តិ PDP-Center | ០១៦ ៨២ ៨២ ១១ |
| ១២.លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ០១២ ៨៧៧ ៨៣៣ |
| ១៣.លោកស្រី ធីតា ឃឹះ | នាយិកាអង្គការសីលកា រ | ០១២ ៨៣ ៨៤ ៦៤ |
| ១៤.លោក ម៉ាក ចំរើន | ប្រធានសមាគមយុវជនខ្មែរ | ០១៧ ៧៨ ៨៩ ៥៥ |
| ១៥.លោក ម៉ម សម្បត្តិ | នាយកប្រតិបត្តិ DPA | ០១២ ៧៧ ៩៧ ៣៤ |
| ១៦.លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ១៧.លោក សាម អ៊ីន | នាយកប្រតិបត្តិ LWD | ០១២ ៥៥ ១៨ ៨៦ |
| ១៨.លោក ណែប ស៊ិនថៃ | នាយក API | ០១២ ៥២ ៧០ ០៤ |
| ១៩.លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ០១២ ៩៤ ២០ ១៧ |